Institut Pasteur du Cambodge

*រៀបរៀងដោយ វេជ្ជ.ហេង ណៃឃីម / វេជ្ជ.ពឹង យ៉ឹកស៊ីង / ខែមេសា ឆ្នាំ២០១៥*

# វ៉ាក់សាំងបង្ការជំងឺគ្រុនពោះវៀន ( Typhoid Fever Vaccine)

## ១- តើវ៉ាក់សាំងបង្ការជំងឺគ្រុនពោះវៀនជាអ្វី?

ជំងឺគ្រុនពោះវៀនគឺជាជំងឺធ្ងន់ធ្ងរមួយដែលបង្កឡើងដោយបាក់តេរី ដែលមានឈ្មោះថា Salmonella Typhi។

ជំងឺគ្រុនពោះវៀនអាចបង្កអោយមានគ្រុនក្ដៅខ្លាំង ល្ហិតល្ហៃ អស់កំលាំង ឈឺពោះ ឈឺក្បាល មិនឃ្លានអាហារ និងពេលខ្លះ មានកន្ទួលលើស្បែក។

ប្រសិនបើមិនមានការព្យាបាលត្រឹមត្រូវទេនោះ វាអាចសំលាប់មនុស្សរហូតដល់ ៣០% នៃអ្នកដែលមានជំងឺនេះ។ មនុស្សមួយចំនួនដែលកើតជំងឺគ្រុនពោះវៀននេះបានក្លាយជា "អ្នកផ្ទុក" ដែលអាចចំលងជំងឺនេះទៅកាន់អ្នកដទៃទៀតបាន។ ជាទូទៅ ជំងឺគ្រុនពោះវៀននេះឆ្លង តាមរយៈចំណីអាហារ និងទឹកមិនស្អាត ។

ចាក់វ៉ាក់សាំងបង្ការជំងឺគ្រុនពោះវៀនអាចបង្ការជំងឺគ្រុនពោះវៀននេះបាន។

## ២- តើអ្នកណាខ្លះដែលគួរទទួលវ៉ាក់សាំងបង្ការជំងឺគ្រុនពោះវៀននេះ? ហើយគួរទទួលនៅពេលណា?

វ៉ាក់សាំងបង្ការជំងឺគ្រុនពោះវៀននេះត្រូវបានណែនាំអោយប្រើសំរាប់៖

- អ្នកដែលធ្វើដំណើរទៅកាន់តំបន់ដែលជំងឺគ្រុនពោះវៀននេះកើតមានញឹកញាប់
- អ្នកដែលរស់នៅជិតដិតនឹងអ្នកផ្ទុកមេរោគគ្រុនពោះវៀន
- អ្នកមន្ទីរពិសោធន៍ដែលប្រឈមនឹងមេរោគនេះ

វ៉ាក់សាំងបង្ការជំងឺគ្រុនពោះវៀននេះត្រូវប្រើសំរាប់មនុស្ស ដែលមានអាយុចាប់ពី ២ឆ្នាំ ឡើងទៅ ដោយចាក់តែមួយដូសគត់។ សំរាប់អ្នកទាំងឡាយណាដែលនៅតែប្រឈមមុខខ្ពស់នឹងការឆ្លងមេរោគនេះ ត្រូវធ្វើការចាក់រំលឹករាល់ ៣ឆ្នាំ ម្ដង។

ដើម្បីអោយវ៉ាក់សាំងបង្ការមានប្រសិទ្ធភាព វាគួរត្រូវបានផ្ដល់យ៉ាងហោចណាស់ ២សប្ដាហ៍ មុនពេលធ្វើដំណើរទៅតំបន់ដែលប្រឈមនឹងជំងឺនេះ។

## ៣- តើអ្នកណាខ្លះដែលមិនគួរទទួលវ៉ាក់សាំងនេះ?

- កុមារដែលមានអាយុតិចជាង ២ឆ្នាំ
- អ្នកដែលធ្លាប់មានប្រវត្តិប្រតិកម្មធ្ងន់ធ្ងរជាមួយនឹងវ៉ាក់សាំងប្រភេទនេះពីមុន ឬធ្លាប់ប្រតិកម្មធ្ងន់ធ្ងរជាមួយសមាសធាតុផ្សំផ្សេងទៀតដែលមានក្នុងវ៉ាក់សាំងនេះ
- អ្នកដែលមានជំងឺកំរិតមធ្យម រឺធ្ងន់ធ្ងរ (ការផ្ដល់វ៉ាក់សាំងនេះគួរត្រូវបានពន្យារពេល រហូតដល់ជាសះស្បើយពីជំងឺជាមុនសិន)។
- អ្នកដែលធ្លាប់មានប្រវត្តិប្រតិកម្មធ្ងន់ធ្ងរជាមួយនឹងវ៉ាក់សាំងប្រភេទនេះពីមុន ឬធ្លាប់ប្រតិកម្មធ្ងន់ធ្ងរជាមួយសមាសធាតុផ្សំផ្សេងទៀតដែលមាន ក្នុងវ៉ាក់សាំងនេះ
- ស្ត្រីដែលកំពុងមានផ្ទៃពោះ

## ៤- ផលវិបាកដែលអាចកើតមានក្រោយចាក់វ៉ាក់សាំង

ដូចឱសថផ្សេងៗទៀតដែរ វ៉ាក់សាំងអាចបណ្ដាលអោយមានផលវិបាកធ្ងន់ធ្ងរ ដូចជាប្រតិកម្មអាលែកស៊ីជាដើម។ ប៉ុន្តែលទ្ធភាពដែលវ៉ាក់សាំងនេះអាចបណ្ដាលអោយមានផលវិបាកធ្ងន់ធ្ងរមានតិចតួចបំផុត។ ផលវិបាកដែលអាចកើតឡើងរួមមាន៖

- ឈឺ ឬ ហើមត្រង់កន្លែងចាក់
- គ្រុនក្ដៅ ឈឺក្បាល
- ឡើងកន្ទួលក្រហមលើស្បែក
- ប្រតិកម្មធ្ងន់ធ្ងរ (កំរមានណាស់)

**ប្រសិនបើមានសញ្ញាប្រតិកម្មធ្ងន់ធ្ងរ សូមជូនដំណឹងដល់គ្រូពេទ្យជាបន្ទាន់!**